ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ooo □ ooo

របាយការណ៍សង្ខេប
សិក្ខាសាលាក្រុមការងាររួមរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីពី មេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា

ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រកពធនធាន
នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

១-សេចក្តីផ្តើម៖

នារសៀលថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តម ទា ផល** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមការងាររួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ដោយមានការចូលរួមពីសំណាក់ លោកស្រី VLADANKA ANDREEVA នាយិកានៃអង្គការយូអិនអេដស៍ (UNAIDS) ប្រចាំព្រះរាជាណាចក្រកម្ពុជា និងជាសហប្រធាននៃអង្គប្រជុំ ដោយមានវត្តមានចូលរួមពីសំណាក់ លោក លោកស្រី តំណាង ស្ថាប័ន ក្រសួងពាក់ព័ន្ធ តំណាងទីភ្នាក់ងារដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ តំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អង្គការសហប្រជាជាតិចំនួន២៣នាក់។

២-របៀបវារៈនៃកិច្ចប្រជុំ៖

- ការទទួលភារកិច្ចជាសហប្រធានក្រុមការងាររួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា របស់លោកស្រី VLADANKA ANDREEVA បន្តពីលោកស្រី Christina Lau តំណាងទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ សហរដ្ឋអាមេរិកប្រចាំកម្ពុជា ព្រមទាំងពិនិត្យពិភាក្សាកែសម្រួលតួនាទី និងភារកិច្ច របស់ក្រុមការងាររួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារប្រយុទ្ធនឹងជំងឺអេដស៍។
- បច្ចុប្បន្នភាពរៀបចំសូចនាករួមតាមដានវាយតម្លៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
- ការរៀបចំទទួលគណៈប្រតិភូក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីអង្គការយូអិនអេដស៍ (UNAIDS) នៅព្រះរាជាណាចក្រកម្ពុជាពីថ្ងៃទី១៧ ដល់ ២១ ខែកុម្ភៈ ឆ្នាំ២០២០។
- ការចូលរួមបដិភាគរបស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍
- ផ្សេងៗ

៣-របាយការណ៍កិច្ចប្រជុំ ៖

ការស្វាគមន៍របស់សហប្រធានអង្គប្រជុំ៖

ឯកឧត្តម ទា ផល អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសំដែងអំណរគុណចំពោះសមាជិក សមាជិកា ដែលបានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមកិច្ចប្រជុំ។

របៀបវារៈទី១ អង្គប្រជុំបានផ្លាស់ប្តូរយោបល់លើការបន្ថែមសមាសភាពនៃក្រុមការងារបច្ចេកទេសរួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារប្រយុទ្ធនឹងជំងឺអេដស៍ ដោយបញ្ចូលសមាសភាពពីក្រុមប្រឹក្សាគាំពារសង្គម ក្រសួងផែនការ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)ផង។ អង្គប្រជុំបានស្នើសុំឱ្យសមាជិក បន្តចូលរួមផ្តល់យោបល់លើសមាសភាព បរិយាយតួនាទី និងភារកិច្ចនៃក្រុមការងារបច្ចេកទេសរួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការងារប្រយុទ្ធនឹងជំងឺអេដស៍ និងផ្ញើមកលេខាធិការដ្ឋាន (អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍) បន្ថែមទៀត។ លេខាធិការដ្ឋាននឹងបន្តទទួលយកយោបល់ ខ្លឹមសារ ដើម្បីសម្រេចជាផ្លូវការចុងក្រោយជូនភ្ជាប់ឯកសារយោងនៃសេចក្តីព្រៀង ។

របៀបវារៈទី២ សូចនាករួមប្រយុទ្ធនឹងជំងឺអេដស៍ ក៏ដូចជាសូចនាករវិស័យផ្សេងទៀតត្រូវបានអនុម័តដោយសម្តេចនាយករដ្ឋមន្ត្រីកាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩។ អង្គប្រជុំបានផ្តល់អនុសាសន៍ឱ្យធ្វើបច្ចុប្បន្នភាព តួលេខ ទិន្នន័យ ជាមួយក្រសួងសុខាភិបាល អង្គភាពពាក់ព័ន្ធ ដើម្បីឱ្យសូចនាករតាមដានរួម ស្របជាមួយតួលេខសូចនាករចុងក្រោយ ដែលមានមុននឹងដាក់ជូនអង្គប្រជុំពិនិត្យពិភាក្សាជាថ្មីទៀត។

របៀបវារៈទី៣ លោកស្រី VLADANKA ANDREEVA បានជម្រាបជូនអង្គប្រជុំថា ក្រុមប្រឹក្សាកម្មវិធីអង្គការយូអិនអេដស៍ (UNAIDS) មានសមាជិក២៨នាក់ មានសមាសភាពពីសភាជាតំណាងអង្គការសហប្រជាជាតិនានា ស្ថាប័នអន្តរជាតិពាក់ព័ន្ធ រួមទាំងតំណាងអង្គការសង្គមស៊ីវិលផង។ គោលបំណងនៃទស្សកិច្ចរបស់សមាជិកក្រុមប្រឹក្សាកម្មវិធីអង្គការយូអិនអេដស៍ (UNAIDS) គឺចង់សិក្សាស្វែងយល់ដោយផ្ទាល់អំពីស្ថានភាពនៃជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជា សិក្សាពីបទពិសោធន៍ ជោគជ័យ និងបញ្ហាប្រឈមដើម្បីដកស្រង់ទៅពិនិត្យជាគោលនយោបាយសកលប្រយុទ្ធនឹងជំងឺអេដស៍។

របៀបវារៈទី៤ អង្គប្រជុំបានពិនិត្យលើតួលេខបដិភាគធនធានថវិកា របស់រាជរដ្ឋាភិបាលនៅក្នុងការប្រយុទ្ធនឹងជំងឺអេដស៍នាពេលកន្លងមក និងបានពិនិត្យលើល័ក្ខខ័ណ្ឌតម្រូវ ដោយមូលនិធិសកល សិក្សាលើការចងក្រងទិន្នន័យ និងព័ត៌មានហិរញ្ញវត្ថុដែលរាជរដ្ឋាភិបាល បានចូលរួមចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍។ អង្គប្រជុំបានឯកភាពទុកលទ្ធភាពជូនអង្គភាពទទួលជំនួយមូលនិធិសកល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចងក្រងតួលេខថវិកា និងបំភ្លឺជូនទៅមូលនិធិសកល និងពិភាក្សាការងារជាបន្តបន្ទាប់ដោយផ្ទាល់ជាមួយមូលនិធិសកល។

នៅកិច្ចបញ្ចប់ **ឯកឧត្តម ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិក សមាជិកា ជាថ្មីម្តងទៀត ចំពោះការអញ្ជើញចូលរួម និងបានផ្តល់មតិយោបល់ ជាធាតុចូលយ៉ាងផុសផុល ក្នុងកិច្ចប្រជុំក្រុមការងាររួមរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា ។

ថ្ងៃចន្ទ ១១រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញថ្ងៃទី២០ ខែមករា ឆ្នាំ២០២០

បានឃើញ និងឯកភាព	**បានឃើញ និងឯកភាព**	ប្រធាននាយកដ្ឋានទាក់ទង
ប្រធានអង្គប្រជុំ	**អគ្គលេខាធិការ**	និងចលនាប្រកពធនធាន
ឯកឧ. ទា ផលា	**ឈឹម យិនដារ៉ែត**	វេជ្ជ ហួត សេរីវុឌ្ឍ